# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤

## ជប៉ុនផ្តល់៥០៩,៧២៣ ដុល្លារអាមេរិកដើម្បីបង្កើនសមត្ថភាពក្រុមបោសសំអាតកាកសំណល់ជាតិផ្ទុះពីសង្រ្គាម



ក្រោមគ្រោងការណ៍នៃជំនួយឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន៥០៩,៧២៣ដុល្លាអាមេរិក ដល់អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកស្រី ហ្វុឈិកាមិ ហិរុមិ ប្រធានតំណាងអង្គការ JMAS ដើម្បីអនុវត្ត "គម្រោងបង្កើនសមត្ថភាពក្រុមបោសសំអាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាម"។



គម្រោងនេះ គឺដើម្បីបង្កើនសមត្ថភាពអប់រំរបស់សាស្ត្រាចារ្យ ក៏ដូចជាបង្កើនសមត្ថភាពគ្រប់គ្រងនៅទីវាលរបស់ ថ្នាក់ដឹកនាំ និងបច្ចេកវិទ្យាសុវត្ថិភាពសម្រាប់សមាជិកក្រុម CMAC ក្រោមជំនួយបច្ចេកទេសពីទីប្រឹក្សារបស់JMAS នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា នៅខេត្តកំពង់ឆ្នាំង។ ជាងនេះទៅទៀត ជាផ្នែកមួយនៃការផ្ទេរបច្ចេកទេសជំនាញរុករកសំណល់ជាតិផ្ទុះពីសង្គ្រាមដែលកប់នៅក្នុងដី នឹងត្រូវបានណែនាំដោយហេតុថាមានគ្រោះថ្នាក់កាន់តែច្រើនបានកើតឡើងដោយសារត្រាក់ទ័រនៅចុងឆ្នាំ ដែលការអភិវឌ្ឍដីធ្លីជាតិកំពុងមានការកើនឡើងនៅប្រទេសកម្ពុជា។ យើងរំពឹងថា គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ ១,៧៤៥,០០០នាក់ ដោយកាត់បន្ថយការគំរាមកំហែងពីសំណល់ជាតិផ្ទុះពីសង្គ្រាម និងឈានទៅដល់ការអភិវឌ្ឍសហគមន៍នៅពេលដែលតំបន់នោះ ត្រូវបានបោសសំអាតរួច។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់ អង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាល ជប៉ុនបានផ្តល់ថវិកាជាង២២.២លានដុល្លាអាមេរិក ដល់គម្រោងចំនួន៨១គម្រោង របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី១តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៤របស់ជប៉ុន(មេសា២០១៤ដល់មិនា២០១៥)។



ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ័ៈ ០២៣-២១៧-១៦១ ទូរសារៈ ០២៣-២១៤-៣៣០
អ៊ីមែលៈ eco.jpn@.pp.mofa.go.jp
គេហទំព័រៈ http://www.kh.emb-japan.go.jp